

# ដំណាំម្នាស់

## ១-ការរៀបចំរងៈ

យើងត្រូវភ្ជួរដីឲ្យបានស្អាត ទុកចោល ១សប្តាហ៍ បន្ទាប់មកកាយចង្អូរ ឬភ្ជួររតូតដែល មានបណ្តោយ ២០ ម៉ែត្រ និងចន្លោះចង្អូរប្រវែង ១ម៉ែត្រ រួចដាក់ជីអាចម៍គោ តាមចង្អូរហើយ លប់ដីពីលើ។

## ២- ការដាំម្នាស់

យើងដាំកូនម្នាស់ពីលើចង្អូរដែលដាក់ជី អាចម៍គោ ដែលមានចន្លោះពីគុម្ពមួយទៅគុម្ពមួយ ប្រវែងពី ៣ ទៅ ៤តឹក និងចន្លោះរង ប្រវែង ពី៦ ទៅ ៨តឹក។ យើងត្រូវកប់គល់កូនម្នាស់ចូលទៅក្នុងដីប្រមាណ ១តឹក។








កប់គល់ចូលដី១តឹក

## ៣- ការសំអាតស្មៅ ពូនគល់ និងការគ្របរងៈ

ស្មៅចាប់ផ្តើមដុះក្រោយយើងដាំរួចរយៈ ពេល ១ខែ យើងត្រូវត្រួតពិនិត្យមើល បើឃើញថា មានស្មៅដុះកំពស់កូនម្នាស់ យើងចាំបាច់ ត្រូវធ្វើការជំរះស្មៅចេញ រួចពូនរងនិងយកស្មៅងាប់ ឬដើមកន្ទ្រាំងខែត្រ ឬអង្កាម ដាក់ពីលើរងអោយបានច្រើន ដើម្បីអោយកើតជាជី និង បន្ថយការលូតលាស់របស់ស្មៅ។

## ៤- ការដាក់ជីៈ

- ❋ ការដាក់ជីទ្រាប់បាតៈ យើងដាក់ជីលាមកសត្វ ប្រមាណ៣ការុង ឬ៣០គីឡូក្រាមពីលើចង្អូររងប្រវែង២០ម៉ែត្ររួចកាប់ជ្រោយ អោយបានសព្វមុនពេលដាំ។
- ❋ ការដាក់ជីបំប៉នៈ យើងប្រើជីអ៊ុយរ៉េ២ដង និង ជី២០-២០-១៥ ១ដងសំរាប់បំប៉នដើមម្នាស់ឲ្យលូតលាស់ល្អ។ ត្រូវសំអាតស្មៅឲ្យបានស្អាតជាមុនសិន និងត្រូវដាក់ជី ក្រោយភ្លៀងធ្លាក់ សំរាប់រដូវវស្សា។ នៅរដូវប្រាំងយើងត្រូវយកជីអ៊ុយរ៉េចំនួន កន្លះគីឡូ ក្រាម លាយទឹក១ធុងចំណុះ២០លីត្រ សំរាប់កូនម្នាស់ ១០០ដើម។ ត្រូវចាក់ស្រោច តាមគល់កុំឲ្យទឹកជីចូលក្នុងបណ្តូលដើមម្នាស់។



- ❋ លើកទី១ៈ ត្រូវដាក់ជីក្នុងរយៈពេល១ ខែ កន្លះ ក្រោយដាំ ប្រើជីអ៊ុយរ៉េ១គ.ក្រ សំរាប់កូនម្នាស់ ២០០ ដើម។
- ❋ លើកទី២ៈ ត្រូវដាក់ជីក្នុងរយៈពេល ២ខែក្រោយ លើកទី១ ប្រើជីអ៊ុយរ៉េ ម្តងទៀត១គ.ក្រ សំរាប់ កូនម្នាស់ ២០០ ដើម។
- ❋ លើកទី៣ៈ ពេលម្នាស់ចាប់ផ្តើមចេញផ្កា ប្រើ ជី២០-២០-១៥ ១គ.ក្រ សំរាប់កូនម្នាស់២០០ ដើម។
- ❋ **ចំណាំៈ** យើងអាចប្រើជីទឹកនោម គ្រាំជាមួយ

លាមកសត្វ និងដើមកន្ទ្រាំងខែត្រ ដោយចាក់ស្រោចតាមគល់ជំនួសជីអ៊ុយរ៉េក៏បាន។ យើងប្រើទឹកជី១ធុងចំណុះ២០លីត្រ សំរាប់ម្នាស់ ១០០ដើម។




ត្រូវយកដីលប់ពីលើជី

## ៥- ស្រោចស្រព:

បើយើងដាំកូនម្នាស់នៅរដូវប្រាំង យើងត្រូវស្រោចទឹកពន្លិចរងក្រោយដាំរួច និងត្រូវស្រោចវារៀងរាល់ ១ខែម្តង រហូតដល់ភ្លៀងធ្លាក់។

## ៦- កាច់សំអាតខ្នែង:

ជាធម្មតាពូជម្នាស់ស្រុកយើងពុំសូវឃើញ មានខ្នែងកូននៅពេលដើមម្នាស់ កំពុងលូលាស់ទេ ប៉ុន្តែយើងគួរតែត្រួតពិនិត្យមើលបើឃើញមានខ្នែង ត្រូវកាច់ចេញ ដោយទុកតែដើមមេមួយប៉ុណ្ណោះ ដើម្បីអោយបានផ្លែធំ។

## ៧- ជំរុញផ្កា:

ដើមម្នាស់អាចចាក់ថ្មស្អុយបានលុះត្រាតែវា មានដើមធំល្អដែលមានស្លឹកលើសពី២០ឡើងទៅ។ យកថ្មស្អុយលេខ១ចំនួន ៣ខាំលាយជាមួយ ទឹក១ ធុងចំណុះ ២០លីត្រ រួចយកទឹកល្បាយនេះចាក់ចូល ក្នុងបណ្តូលដើមម្នាស់ទាល់តែពេញ។ ជាធម្មតា ល្បាយទឹកថ្មស្អុយ ២០លីត្រ អាចចាក់បាន៣រង ប្រវែង២០ម៉ែត្រ។ ក្រោយចាក់ថ្មស្អុយរយៈពេល ៤ ខែ២០ថ្ងៃទើបម្នាស់ទុំអាចកាច់យកលក់បាន។



ចាក់ល្បាយទឹកថ្មស្អុយទាលើតែពេញ

## ឯកសារពិគ្រោះ៖


- Traing module on fruit tree production, 2013 (គណៈកម្មការអភិវឌ្ឍន៍ដំណាំឈើហូបផ្លែ នៅខេត្តតំបន់៣យព្យ)
- បទពិសោធន៍ ងួន ង៉ាន់ កសិករដាំម្នាស់, 2011 (ឃុំព្រែកជីក ស្រុកមោងឬស្សី ខេត្តបាត់ដំបង)



សម្រាប់ព័ត៌មានលម្អិតសូមទំនាក់ទំនងមកនាយកដ្ឋានផ្សព្វផ្សាយកសិកម្មតាមសយដ្ឋានខាងក្រោម:
លេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ : (០២៣)-២១៥ ៨១៩/០១២ ៨២៦ ៦១៧



ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម


# បទពិសោធន៍ជោគជ័យ ក្នុងការដាំម្នាស់ របស់កសិករគំរូ




សហការផលិតដោយ៖
នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និងកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់ ខេត្តសៀមរាប
ឆ្នាំ២០១៣